ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣០...... ព.ណ......ស.ក.ក

ភ្នំពេញ, ថ្ងៃទី ២៧ ខែ ៩ ឆ្នាំ ២០០៧

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ការតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា និងការស្រាវជ្រាវរកកំណត់ត្រាតាមមធ្យោបាយអេឡិចត្រូនិច

អនុលោមតាមច្បាប់ស្ដីពី ប្រតិបត្តិការដែលមានកិច្ចធានា ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០៥០៧/០១២ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៧ និង អនុលោមតាម ប្រកាសអន្តរក្រសួងស្ដីពី កម្រៃសេវាតម្កល់ និងស្រាវជ្រាវលិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា លេខ ៨២៥ សហវ.ប្រក.ចមព ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៧ ។ ក្រសួងពាណិជ្ជកម្ម សូមប្រកាសជូនដំណឹងដល់សាធារណៈជនអោយបានជ្រាបថា: ការតម្កល់លិខិតជូនដំណឹង ជាមួយការិយាល័យតម្កល់លិខិតជូនដំណឹងនៃក្រសួងពាណិជ្ជកម្ម សាធារណៈជនអាចធ្វើតាមមធ្យោបាយអេឡិចត្រូនិចតាមរយៈគេហទំព័រ www.setfo.gov.kh ។

១. តាមរយៈគេហទំព័ររបស់ការិយាល័យតម្កល់លិខិតជូនដំណឹង សាធារណៈជនអាច :

- តម្កល់លិខិតជូនដំណឹងដំបូង
- តម្កល់វិសោធនកម្មលើលិខិតជូនដំណឹង
- តម្កល់លិខិតសុំបន្ត
- តម្កល់លិខិតសុំកែតម្រូវ
- តម្កល់លិខិតសុំបញ្ចប់

២. សាធារណៈជនអាចមកធ្វើការបញ្ជាក់លើកំណត់ត្រានៃការតម្កល់នៅការិយាល័យតម្កល់លិខិតជូនដំណឹងនៃនាយកដ្ឋាននីតិកម្ម ក្រសួងពាណិជ្ជកម្មបានរាល់ម៉ោងធ្វើការ ។

សេចក្ដីជូនដំណឹងនេះត្រូវអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម ស៊ីថន

ចំលងជូន
- មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង ដើម្បីផ្សព្វផ្សាយ
- ឯកសារ - កាលប្បវត្តិ

Ministry of Commerce. # 20 A & B Preah Norodom Boulevard. Phnom Penh (Kingdom of Cambodia)
Hand Phone : 016 861 616 - 016 988 858 - 016 818 825 - ( 023 ) 725 585 Facsimile : ( 855 ) 23 426 396